**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥០៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ៦៥៩,១៨ហិកតា នៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ចេញពីដីតម្រមព្រៃឈើ ឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ ៣១៤ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ



www.pheakdeylaw.com

- បានឃើញអនុក្រឹត្យលេខ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ៩៧៨អបខ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១**: ត្រូវបានកាត់ដីទំហំ ៦៥៩,១៨ ហិកតា ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មដីទំហំ ៦២៦,៥៩ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងដីទំហំ ៣២,៥៩ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិបន្ទាយរកា ឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ តាមប្រព័ន្ធកូអរដោនេ Projection UTM Zone 48N Datum WGS 84 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី ១ និងឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៣១៩គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែងនៅភូមិបន្ទាយរកា ឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។

**មាត្រា ៣**: ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាល នៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០៩ ខែវិច្ឆិកា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*



www.pheakdeylaw.com

ឧបសម្ព័ន្ធ ១ នៃអនុក្រឹត្យលេខ ៥០៩ អនក្រ.បក ចុះថ្ងៃទី ០៧ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការកាត់ឆ្វៀលផ្ទៃដីសរុបទំហំ ១១២,២៤ ហិកតា ចេញពីផែនទីតំបន់ព្រៃឈើ ឆ្នាំ២០០២ ដែលក្នុងនោះគ្រោងបានធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ១០៨,៦៦ ហិកតា ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងជាំជុះជាក់ស្តែង ចំនួន ១២ គ្រួសារ និងរក្សាទុកជាដីសាធារណៈរបស់រដ្ឋ ទំហំ ៣,៥៨ ហិកតា នៅភូមិមន្ទាយរកា ឃុំក្រាំងជីវ៉ាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ




តារាងចំណុចនិយាមកា

| ID | X | Y | ID | X | Y | ID | X | Y | ID | X | Y | ID | X | Y | ID | X | Y |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| តំបន់ I | | | តំបន់ II | | | 31 | 403106 | 1260930 | 47 | 402402 | 1261150 | 63 | 402255 | 1261830 | 78 | 400970 | 1261970 |
| 1 | 403790 | 1261290 | 16 | 403092 | 1262070 | 32 | 403031 | 1260830 | 48 | 402383 | 1261150 | 64 | 402519 | 1261960 | 79 | 400852 | 1261900 |
| 2 | 403709 | 1261230 | 17 | 403119 | 1261630 | 33 | 402963 | 1260820 | 49 | 402375 | 1261190 | 65 | 402677 | 1262060 | 80 | 400657 | 1261750 |
| 3 | 403688 | 1261210 | 18 | 403107 | 1261510 | 34 | 402976 | 1260750 | 50 | 402355 | 1261180 | 66 | 402795 | 1262030 | 81 | 400577 | 1261740 |
| 4 | 403590 | 1261210 | 19 | 403090 | 1261400 | 35 | 402944 | 1260730 | 51 | 402333 | 1261230 | 67 | 402838 | 1262060 | 82 | 400488 | 1261740 |
| 5 | 403561 | 1261240 | 20 | 403063 | 1261360 | 36 | 402928 | 1260710 | 52 | 402314 | 1261230 | 68 | 402842 | 1262150 | 83 | 400475 | 1261820 |
| 6 | 403546 | 1261260 | 21 | 403061 | 1261320 | 37 | 402898 | 1260710 | 53 | 402232 | 1261320 | 69 | 402963 | 1262110 | 84 | 400686 | 1261890 |
| 7 | 403527 | 1261280 | 22 | 403031 | 1261320 | 38 | 402894 | 1260750 | 54 | 402282 | 1261370 | តំបន់ III | | | 85 | 400712 | 1261930 |
| 8 | 403481 | 1261290 | 23 | 403005 | 1261290 | 39 | 402842 | 1260750 | 55 | 402282 | 1261390 | 70 | 401512 | 1261980 | 86 | 400689 | 1262050 |
| 9 | 403492 | 1261340 | 24 | 402988 | 1261250 | 40 | 402832 | 1260790 | 56 | 402213 | 1261570 | 71 | 401504 | 1261870 | 87 | 400701 | 1262090 |
| 10 | 403562 | 1261330 | 25 | 402986 | 1261200 | 41 | 402884 | 1260820 | 57 | 402208 | 1261600 | 72 | 401498 | 1261740 | 88 | 400720 | 1262160 |
| 11 | 403556 | 1261320 | 26 | 403006 | 1261170 | 42 | 402856 | 1260850 | 58 | 402221 | 1261650 | 73 | 401427 | 1261750 | 89 | 400770 | 1262160 |
| 12 | 403564 | 1261300 | 27 | 403061 | 1261080 | 43 | 402770 | 1260810 | 59 | 402212 | 1261710 | 74 | 401352 | 1261760 | 90 | 401066 | 1262100 |
| 13 | 403633 | 1261290 | 28 | 403125 | 1261040 | 44 | 402573 | 1261000 | 60 | 402170 | 1261730 | 75 | 401212 | 1261810 | 91 | 401085 | 1262080 |
| 14 | 403704 | 1261290 | 29 | 403141 | 1261020 | 45 | 402467 | 1261090 | 61 | 402161 | 1261820 | 76 | 401152 | 1261860 | 92 | 401187 | 1262070 |
| 15 | 403755 | 1261290 | 30 | 403140 | 1260980 | 46 | 402434 | 1261110 | 62 | 402251 | 1261800 | 77 | 401072 | 1261980 | 93 | 401267 | 1262050 |

www.pheakdeylaw.com

ឧបសម្ព័ន្ធ ២ នៃអនុក្រឹត្យលេខ...៥០៩...អនក្រ.បក.............ចុះថ្ងៃទី៨...ខែវិច្ឆិកា..ឆ្នាំ២០១៣ ស្ដីពីការកាត់ឆ្វៀលដីសរុបទំហំ ៥៤៦,៩៤ ហិកតា ចេញពីដែនទីតំបន់ព្រៃឈើ ឆ្នាំ២០០២ ដែលក្នុងនោះត្រូវបានធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ចំនួនផ្ទៃដីទំហំ ៥១៧,៩៣ ហិកតា ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងជាំរុះជាក់ស្ដែង ចំនួន ៣០២ គ្រួសារ និងរក្សាទុកជាដីសាធារណៈរបស់រដ្ឋ ទំហំ ២៩,០១ ហិកតា នៅភូមិបន្ទាយរកា ឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ

